# បានត្រឹមខកចិត្ត

*ពាក្យ៩ជាប់ទង*

ដឹងដែលពៅ នៅតែគិត ពិតឈឺចាប់
ដេកមើលសារ ថាអូនផ្ញើរ ស្មើរាល់ដង
ទ្រព្យសស័ក្តិដាក់ទំងន់ពន់គ្រាំចិត្ត
បានតែព្រួយមួយជីវិតគិតយ៉ាងណា
មុខមិនស្រស់ម្លោះជាប់ស្នេហ៍ថៃម្នាក់ឯង
ចង់សងស្នេហ៍តែខ្លាចឃ្លាវាមិនគួរ
តាមគេថាចារចចឹកដឹកដាក់ផ្នឹម
អាចសាងសុខ ចុកចាប់ខ្វាយ ឆ្ងាយជ្រុលជ្រោះ
តែចិត្តបង ហ្មងស្មុកស្មាញ់ សាញ់មិនឈប់
ឲ្យទ្រូងឈឺព្រឺភ័យព្រួចល្ងួចតែគិត
ឈឺនោះឈឺឮដល់គេរអៀនខ្មាស
សួររឿងខ្ញុំមុមលាផ្តាច់កាច់ដាច់អស់
បងដឹងហើយត្រើយគ្រានស្រីអ្វីបងចេះ
ឃ្លាតហើយស្ងួនន្ងួនបងទៅនៅនឹកគ្នា

តឹងស្មើស្លាប់ រ៉ាប់មិនរួច គួចចិត្តប៉ង
ពាក្យឆ្លើយឆ្លង បងបានល្ងើយ ស្បើយទុក្ខា។
មកបាំងបិទ ចិត្តខ្លាំងកាច ខ្លាចចេស្តា
គ្មានខ្លឹមសារ ណាឲ្យប្រុស ស្រុះចិត្តស្រួល។
សែនចម្បែង សែងមិនរួច ផ្តួចចុកខ្យល
ចិត្តចង់សួរ ជ្រួលច្របល់ ខ្វល់មិនលោះ។
គេសង្ឃឹម នឹមស្នេហ៍យើង ទ្រើងខ្ពង់ខ្ពស់
យើងមានឈ្មោះ ព្រោះយល់ចិត្ត ត្បិតប៉ងពិត។
ព្រួយរាល់យប់ ទប់មិនឈ្នះ ជះរួមរិត
តែវមិត្រ និត្យនេបក្បែរ ស្នេហ៍គេសោះ។
ទាំងក្មេងចាស់ ដាស់រុករាន គ្មានចន្លោះ
បានស្រណោះ ម្លោះក្អួតឈាម រាមរងារ។
ជាចំណោះ ម្លេះបងដឹង សឹងលែងទា
យើងជួបជា លាចាកស្នេហ៍ តែនៅរាប់

*ភ្នំពេញ ថ្ងៃទី១៣កម្ភៈ ២០០៥*

*សូយ ឡូត*